00708144

E50/3/1/4.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 06 / 2011
ម៉ោង (Time/Heure): 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៤)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(04)

| | |
|---|---|
| នៅចំពោះ៖ | ចៅក្រម គង់ ស្រ៊ឹម ជាប្រធាន |
| | ចៅក្រម Motoo Noguchi |
| | ចៅក្រម សោម សិរិវឌ្ឍ |
| | ចៅក្រម Agniezska KLONOWIECKAMILART |
| | ចៅក្រម ស៊ិន រិទ្ធិ |
| | ចៅក្រម C. N. Jayasinghe |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ |
| ភាសាដើម | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# មតិជំទាស់មួយផ្នែករបស់ចៅក្រម NOGUCHI
# សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែង

---

SUPREME COURT CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE DE LA COUR SUPRÊME

០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក(០៤)

ឯកសារលេខ.E50/3/1/4.1

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីជនជាប់ចោទ ខៀវ សំផន**
ស សូវាន
Jacques VERGÈS

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU FORT

១ មតិជំទាស់របស់ខ្ញុំ គឺពាក់ព័ន្ធនឹងមូលដ្ឋានទី២ នៃបណ្ដឹងសាទុក្ខ (វិធាន ៦៣(៣))។ ការបកស្រាយរបស់ខ្ញុំចំពោះបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃវិធានផ្ទៃក្នុង ខុសគ្នាពីការបកស្រាយរបស់ចៅក្រមភាគច្រើនទៀត។ តាមការយល់ឃើញរបស់ខ្ញុំ វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបានទេចំពោះការការរក្សាជនជាប់ចោទក្នុងឃុំខ្លួនក្នុងដំណាក់កាលជំនុំជម្រះ ហើយក្នុងករណីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងគួរតែបានបន្តឃុំខ្លួនជនជាប់ចោទ ដោយផ្អែកតែលើមូលដ្ឋាននៃវិធាន ៨២(១) មួយប៉ុណ្ណោះ។ គំនិតនេះ ដូចគ្នានឹងទស្សនៈរបស់សហព្រះរាជអាជ្ញាក្នុងចម្លើយតបរបស់ខ្លួន[១]។ ហេតុផលរបស់ខ្ញុំមានដូចតទៅនេះ៖

២ វិធាន ៦៣ ដែលមានចំណងជើងថា "ការឃុំខ្លួនបណ្ដោះអាសន្ន" ពាក់ព័ន្ធនឹងការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នក្នុងដំណាក់កាលស៊ើបអង្កេតតាមផ្លូវតុលាការ ដែលចេញដីកាបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត។ ខ្លឹមសារនៃបទប្បញ្ញត្តិនេះ រួមទាំងទីតាំងរបស់វានៅក្នុងវិធានផ្ទៃក្នុង (ជំពូក ៣, នីតិវិធី, គ-ការស៊ើបអង្កេតតាមផ្លូវតុលាការ) មានភាពច្បាស់លាស់។ វិធាន ៨២ ដែលមានចំណងជើងថា "ការឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្ន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ពាក់ព័ន្ធនឹងការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន នៅក្នុងដំណាក់កាលជំនុំជម្រះ។ ខ្លឹមសារនៃបទប្បញ្ញត្តិនេះ រួមទាំងទីតាំងរបស់វានៅក្នុងវិធានផ្ទៃក្នុង (ផ្នែកទី៣, នីតិវិធី, ឃ-កិច្ចដំណើរ ការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលា ដំបូង) មានភាពច្បាស់លាស់។

៣ ខ្ញុំយល់ឃើញថា វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបានចំពោះការបន្តឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ននៅក្នុងដំណាក់កាលជំនុំជម្រះទេ។ ចំណុចនេះមានភាពច្បាស់លាស់ដូចពោលខាងលើស្រាប់ គឺវិធាន ៦៣ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ននៅក្នុងដំណាក់កាលស៊ើបអង្កេតតាមផ្លូវតុលាការ។ ចំណែកឯ វិធាន ៨២ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន នៅក្នុងដំណាក់កាលជំនុំជម្រះ។ នៅក្នុងរចនាសម្ព័ន្ធនៃវិធានផ្ទៃក្នុង គេដាក់បទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធី ដែលមានលក្ខណៈរួមលើសពីមួយផ្នែកនៃកិច្ចដំណើរការនីតិវិធី ឬ ស្ថាប័នតុលាការ នៅក្រោមផ្នែក ដែលមានចំណងជើងថា "ជំពូក ៣ នីតិធិវិធី, ក-បទប្បញ្ញត្តិទូទៅ"។ បទប្បញ្ញត្តិស្ដីពីនីតិវិធីណាដែលពាក់ព័ន្ធតែផ្នែកមួយនៃកិច្ចដំណើរការនីតិវិធី ឬ ស្ថាប័នតុលាការ គេដាក់នៅក្រោមផ្នែកពិសេសសម្រាប់តែផ្នែកនៃកិច្ចដំណើរការនីតិវិធី ឬ ស្ថាប័នតុលាការ

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១-១៤



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME * E.C.C.C * C.E.T.C *

នោះប៉ុណ្ណោះ ដូចជា "គ-ការស៊ើបអង្កេតតាមផ្លូវតុលាការ" និង "ង- នីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ ក្នុងករណីមានការចាំបាច់តម្រូវឱ្យមានការកែប្រែ ដើម្បីអនុវត្តបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងផ្នែកមួយនៃកិច្ចដំណើរការនីតិវិធី ឬស្ថាប័នតុលាការ ទៅក្នុងផ្នែកមួយទៀតនៃកិច្ចដំណើរការនីតិវិធី ឬស្ថាប័នតុលាការ នោះគេត្រូវដាក់បទប្បញ្ញត្តិ ឬចំណុចយោងនោះ ទៅក្នុងផ្នែកក្រោយៗទៀត[២]។ នៅក្នុងវិធានផ្ទៃក្នុង ពុំមានបទប្បញ្ញត្តិណាដែលចែងថា វិធាន ៦៣ នៃវិធានផ្ទៃក្នុង អាចយកមកអនុវត្តចំពោះដំណាក់កាលជំនុំជម្រះបាននោះទេ។ ករណីលើកលែងតែមួយនៃវិធាន ៨១(២) នៃវិធានផ្ទៃក្នុង ត្រូវបានពន្យល់ដូចខាងក្រោម៖

៤ វិធាន ៨១(២) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងជនជាប់ចោទដែលពុំស្ថិតក្នុងឃុំនៅពេលសវនាការ។ ប្រយោគចុងក្រោយនៃវិធាននេះចែងថា "ជនជាប់ចោទត្រូវនាំមកកាន់មន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រហូតដល់ពេលជនជាប់ចោទរូបនេះត្រូវបានមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើការឃុំខ្លួនជនជាប់ចោទនោះ ស្របតាមវិធាន ៦៣ (មានការបញ្ជាក់បន្ថែម)។ សេចក្ដីយោងនេះមានលក្ខណៈច្បាស់លាស់ដែលចែងថា វិធាន ៦៣ នៃវិធានផ្ទៃក្នុង ដែលជាបទប្បញ្ញត្តិស្ថិតនៅក្រោមផ្នែក "គ-ការស៊ើបអង្កេតតាមផ្លូវតុលាការ" អនុវត្តបានចំពោះស្ថានភាពដូចមានចែងក្នុងវិធាន ៨១(២) នៃវិធានផ្ទៃក្នុង ដែលជាបទប្បញ្ញត្តិមួយមានចែងនៅក្នុងផ្នែក "ង-កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ ដូចគ្នាផងដែរ មាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទដែលជាប់ឃុំឱ្យមានសេរីភាពវិញបាន ឬឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ដោយយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ" (មានការបញ្ជាក់បន្ថែម)។ សេចក្ដីយោងនេះ គឺមានលក្ខណៈច្បាស់លាស់ដោយចែងថា មាត្រា ២០៥ ដែលជាបទប្បញ្ញត្តិដែលមានចែងក្នុង "គន្ថី ៤, ការស៊ើបអង្កេតតាមផ្លូវតុលាការ" អនុវត្តបានចំពោះស្ថានភាពដូចមានចែងក្នុងមាត្រា ៣០៦ ដែលជាបទប្បញ្ញត្តិមួយក្នុង "គន្ថី ៥, សាលក្រម"។

៥ ផ្ទុយទៅវិញ ប្រយោគទី១ នៃវិធាន ៨២(២) នៃវិធានផ្ទៃក្នុង ចែងថា "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឬដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងករណីចាំបាច់ ឬបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបានស្របតាមវិធានផ្ទៃក្នុងទាំងនេះ" (មានការបញ្ជាក់បន្ថែម)។ ដោយសារតែពុំមានចំណុចយោងពិសេសទៅនឹងវិធាន ៦៣ នៃវិធានផ្ទៃក្នុង

[២] *ឧទាហរណ៍* វិធាន ១០៤ ស្ទួន



SUPREME COURT CHAMBER DE LA COUR SUPRÊME * E.C.C.C * C.E.T.C * 4

ជាការសមហេតុផលគេអាចបកស្រាយឃ្លា "<u>ស្របតាមវិធានផ្ទៃក្នុងទាំងនេះ</u>" ថាជាការយោងទៅនឹងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានាទាំងក្នុងផ្នែក "ក-បទប្បញ្ញត្តិទូទៅ" ឬ "ង-កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ក៏បាន។

៦ ចៅក្រមភាគច្រើនយល់ស្របគ្នាថា វិធាន ៨២ នៃវិធានផ្ទៃក្នុង គប្បីអានផ្គួបគ្នាជាមួយមាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ខ្ញុំមិនគាំទ្រការយល់ឃើញបែបនេះនោះទេ។ បទប្បញ្ញត្តិជាច្រើននៃវិធានផ្ទៃក្នុងមានប្រភពមកពីបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលកាលពេលនោះនៅជាសេចក្តីព្រាងត្រៀមបញ្ជូនទៅអង្គនីតិបញ្ញត្តិកម្ពុជានៅឡើយ គឺនៅចំពេលដែលវិធានផ្ទៃក្នុងត្រូវបានអនុម័តជាលើកដំបូងក្នុងឆ្នាំ ២០០៧។ ទោះជាយ៉ាងនេះក្តី វិធានផ្ទៃក្នុងគឺជាឯកសារច្បាប់ឯករាជ្យ និងពិសេសមួយ ដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា និងសម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដើម្បីអនុម័តវិធានមួយចំនួនបន្ថែមទៀត សម្រាប់ករណីពិសេសណាមួយ[៣]។ ដោយសារតែអាណត្តិ យុត្តាធិការ និងរចនាសម្ព័ន្ធពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានបទប្បញ្ញត្តិជាច្រើន នៅក្នុងវិធានផ្ទៃក្នុង ដែលពុំមាន ឬខុសគ្នាពីនីតិវិធីសម្រាប់ជំនុំជម្រះរឿងក្តីធម្មតានៅថ្នាក់ជាតិដោយតុលាការធម្មតារបស់ជាតិ។ ដូច្នេះ បរិបទសម្រាប់ការបកស្រាយវិធានផ្ទៃក្នុងបាន គឺគេចាំបាច់ និងសំខាន់បំផុត ត្រូវតែផ្អែកលើវិធានផ្ទៃក្នុងនេះតែប៉ុណ្ណោះ។ បើមិនដូច្នេះទេ អ្នកអានវិធានផ្ទៃក្នុង នឹងពិបាកយល់ដឹងឱ្យបានច្បាស់អំពីអ្វីជាវិធាននីតិវិធីពិតប្រាកដនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការយោងទៅរកការណែនាំពីបទប្បញ្ញត្តិទាំងឡាយ ដែលស្រដៀងគ្នានៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចមានប្រយោជន៍ ប៉ុន្តែអាស្រ័យលើកាលៈទេសៈផងដែរ។ ក្នុងពេលដែលអត្ថន័យនៃបទប្បញ្ញត្តិជាក់លាក់ណាមួយនៃវិធានផ្ទៃក្នុង មានន័យច្បាស់លាស់គ្រប់គ្រាន់ក្នុងបរិបទរបស់វារួចហើយនោះ ការងាកទៅពឹងផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាការមិនចាំបាច់ទេ។

៧ បន្ទាប់ទៅនេះ ខ្ញុំនឹងពិនិត្យមើលរចនាសម្ព័ន្ធនៃការឃុំខ្លួននៅដំណាក់កាលជំនុំជម្រះ ដូចដែលមានចែងក្នុងវិធាន ៨២(១)-(៣) នៃវិធានផ្ទៃក្នុង។ ប្រយោគដំបូងនៃវិធាន ៨២(១) កំណត់យកសេរីភាពជាវិធានទូទៅមួយ ដោយចែងថា "ជនជាប់ចោទ<u>ត្រូវមានសេរីភាពរហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែ</u>មានការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នដូចមានចែង

[៣] វិធានផ្ទៃក្នុង បុព្វកថា កថាខណ្ឌ ៥

ក្នុងវិធានផ្ទៃក្នុងនេះ" (មានការបញ្ជាក់បន្ថែម)។ ប្រយោគទីពីរនៃវិធាន ៨២(១) ចែងថា "ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែល រហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសម្រេចសេចក្តី លើកលែងតែករណីដែលមានចែងក្នុងអនុវិធាន ២ ខាងក្រោម" (មានការបញ្ជាក់បន្ថែម)។ ដូច្នេះ ប្រយោគទីពីរនេះ គឺជាករណីលើកលែងមួយខុសពីវិធានទូទៅនៃសេរីភាព ដែលមានចែងក្នុងប្រយោគទីមួយនៃវិធាន ៨២(១)។ ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទ *ត្រូវ*ស្ថិតនៅក្នុងឃុំដដែល មានន័យថា ការបន្តឃុំខ្លួន គឺជាកិច្ចដែលត្រូវតែធ្វើដោយស្វ័យប្រវត្តិ និងជាកាតព្វកិច្ច លើកលែងតែជនជាប់ចោទត្រូវបានដោះលែងដោយអនុលោមតាមវិធាន ៨២(២)។ ចំណុចនេះមានភាពខុសគ្នាយ៉ាងប្រត្យក្សទៅនឹងការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបអង្កេត ដែលក្នុងដំណាក់នោះ សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាបង្គាប់មួយជាចំបាច់ និងត្រូវតែបំពេញទៅតាមលក្ខខណ្ឌនៃវិធាន ៦៣(៣)។ ប្រការនេះ មានភាពខុសគ្នាផងដែរពីការឃុំខ្លួនដែលមានចែងក្នុងវិធាន ៨១(២) ដែលក្នុងករណីជនជាប់ចោទនៅក្រៅឃុំ ពុំបានចូលមកបង្ហាញខ្លួនក្នុងសវនាការ និងដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចឃុំខ្លួនជនជាប់ចោទ អនុលោមទៅតាមវិធាន ៦៣។

៨ វិធាន ៨២(២) នៃវិធានផ្ទៃក្នុងចែងថា "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬ បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបានស្របតាមវិធានផ្ទៃក្នុងនេះ" (មានការបញ្ជាក់បន្ថែម)។ ពាក្យថា "អាច" មានន័យថា ការដោះលែងនេះ គឺអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ឬ អាចនិយាយបានថា លើកលែងតែអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីដោះលែងជនជាប់ចោទ ការឃុំខ្លួននឹងត្រូវតែបន្ត ដោយអនុលោមតាមវិធាន ៨២(១)។ វិធាន ៨២(៣) ចែងបន្ថែមទៀតថា ជនជាប់ចោទអាចស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងគាត់។ បន្ទាប់ពីបានទទួលសំណើនេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចក្នុងរយៈពេល ៣០ថ្ងៃ លើកលែងតែមានកាលៈទេសៈ ពិសេសដែលតម្រូវឲ្យមានរយៈពេលយូរជាងនេះ។

៩ ខុសពីការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបអង្កេត ដែលក្នុងនោះលក្ខខណ្ឌត្រូវបានបំពេញគ្រប់ទៅតាមអ្វីដែលមានចែងក្នុងវិធាន ៦៣(៣) វិធានផ្ទៃក្នុងពុំមានចែងថាតើកត្តាអ្វីខ្លះដែលអង្គជំនុំជម្រះសាលាដំបូង គប្បីយកមកពិចារណាក្នុងបរិបទនៃវិធាន ៨២(២) និង (៣) នោះទេ។

គេទុកឱ្យអង្គជំនុំជម្រះសាលាដំបូង ជាអ្នកអនុវត្តឆន្ទានុសិទ្ធិ ដើម្បីសម្រេចថាតើកត្តាអ្វីខ្លះដែលខ្លួនគួរយកមកពិចារណា។ លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) ដូចជា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ គឺមានលក្ខណៈពាក់ព័ន្ធតិចតួចណាស់ទៅនឹងដំណាក់កាលជំនុំជម្រះនេះ ដ្បិតជនជាប់ចោទ ត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយរួចទៅហើយ។ លក្ខខណ្ឌទាំងប្រាំដែលមានចែងក្នុងវិធាន ៦៣(៣)(ខ) អាចនៅជាកត្តាដែលពាក់ព័ន្ធក្នុងដំណាក់កាលជំនុំជម្រះនេះ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង ពុំជាប់កាតព្វកិច្ចដោយកត្តាទាំងនេះទេ និងខ្លួនអាចមានបំណងពិចារណាកត្តាដទៃទៀត ដែលពុំមានចែងក្នុងវិធាន ៦៣(៣)(ខ) បានផងដែរ។ ឧទាហរណ៍ ដូចនៅសាលាក្តី ICTY ទោះបីជាលក្ខខណ្ឌអប្បបរមា សម្រាប់ការដោះលែង ត្រូវបានបំពេញរួចហើយយ៉ាងណាក្តី[៤] ក៏អង្គជំនុំជម្រះសាលាដំបូង នៅតែមានឆន្ទានុសិទ្ធិ ដើម្បីសម្រេចមិនដោះលែងជនជាប់ចោទជាបណ្តោះអាសន្នបាន ប្រសិនបើកាលៈទេសៈនៃរឿងក្តីនោះអនុញ្ញាតឱ្យខ្លួនធ្វើដូច្នេះបាន[៥]។

១០ ប៉ុន្តែ ប្រការនេះពុំមានន័យថា ការបន្តឃុំខ្លួនក្នុងដំណាក់កាលជំនុំជម្រះ អាចធ្វើបានតាមតែអំពើចិត្ត ដោយបំពានលើមាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ[៦]។ ដំបូង ដូចបានបញ្ជាក់ខាងដើមរួចមកហើយ ករណីលើកលែងនៅក្នុងប្រយោគទីពីរនៃវិធាន ៨២(១) តម្រូវឱ្យជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំ នៅក្នុងពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ទីពីរ ជាករណីទូទៅ អង្គជំនុំជម្រះសាលាដំបូងត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យ

---

[៤] វិធាន ៦៥(ខ) នៃវិធាននីតិវិធី និង ភស្តុតាងនៃសាលាក្តី ICTY ចែងថា "ការដោះលែង អាច ត្រូវចេញដីកាបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូងបាន តែក្នុងករណីបន្ទាប់ពីតុលាការបានផ្តល់ឱកាសឱ្យមានសវនាការនៅក្នុងប្រទេសម្ចាស់ផ្ទះ និងរដ្ឋដែលជនជាប់ចោទស្នើសុំដោះលែងនោះ និងក្នុងករណីដែលតុលាការរកឃើញថា បន្ទាប់ពីដោះលែងជនជាប់ចោទរូបនោះនឹងមកបង្ហាញខ្លួនក្នុងពេលជំនុំជម្រះ និងគាត់នឹងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះណាម្នាក់ ឬ សាក្សី ឬជនដទៃទៀតតែប៉ុណ្ណោះ" (មានការបញ្ជាក់បន្ថែម)។ វិធាន ៦៥(ខ) ពុំបានចែងអំពីលក្ខខណ្ឌជាក់លាក់ចំពោះការឃុំខ្លួននោះទេ ប៉ុន្តែបានចែងបញ្ជាក់អំពីលក្ខខណ្ឌអប្បបរមាសម្រាប់ការដោះលែង។

[៥] *ឧទាហរណ៍* សហព្រះរាជអាជ្ញា ទល់នឹង Gotovina et al សំណុំរឿងលេខ IT-06-90-T, សេចក្តីសម្រេចលើបណ្តឹងសុំដោះលែង Ivan Cermak ជាបណ្តោះអាសន្ន T. Ch. I, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៥ និង ១១។

[៦] មាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "ជនគ្រប់រូបមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"។

Original EN: 00705160-00705165

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

សមហេតុសមផល និងសេចក្តីសម្រេចរបស់ខ្លួនត្រូវតែមានសំអាងហេតុ[៧]។ ជាពិសេស វិធាន ២១(២) ចែងថា "<u>វិធានការចាប់បង្ខំទាំងឡាយណា</u>ចំពោះបុគ្គលណាម្នាក់ <u>ត្រូវធ្វើឡើងដោយ ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ វិធានការនេះត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃកិច្ចដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលបានចោទប្រកាន់ និង ដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឱ្យបានពេញលេញ</u>" (មានការបញ្ជាក់បន្ថែម)។ ចំណុចនេះត្រូវអនុវត្តពាក់ព័ន្ធនឹងសេចក្តីសម្រេចដោយអនុលោមទៅតាមវិធាន ៨២(២) និង (៣)។ មិនតែប៉ុណ្ណោះ សេចក្តីស្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបើកផ្លូវឱ្យប្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

១១ លើសពីនេះទៅទៀត ខ្ញុំក៏ពុំឃើញមានភាពផ្ទុយគ្នារវាងវិធាន ៨២(១) និង មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងប្រយោគទីពីរនោះដែរ[៨]។ ដូចខ្ញុំបានពន្យល់រួចមកហើយ វិធាន៨២ ចែងអំពីគោលការណ៍ទូទៅនៃសេរីភាព និងការឃុំខ្លួនជាករណីលើកលែងមួយ។ វិធាននេះក៏បានចែងអំពីច្រកនៃការដោះលែងទាំងតាមរយៈគំនិតផ្តួចផ្តើមផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូង ឬតាមរយៈការស្នើសុំរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានសមហេតុសមផល និងសេចក្តីសម្រេចរបស់ខ្លួនត្រូវតែមានសំអាងហេតុ។ ពិតណាស់ ការឃុំខ្លួនគឺពុំមែនជាវិធានទូទៅនៅក្រោមរចនាសម្ព័ន្ធនេះទេ។

---

[៧] សូមមើល *ឧទាហរណ៍* ព្រះរាជអាជ្ញា ទល់នឹង Nikola Sainovic និង Dragoljub Ojdanic, IT-99-37-AR65, សេចក្តីសម្រេចលើការដោះលែងជាបណ្តោះអាសន្ន App. Ch., ថ្ងៃទី ៣0 ខែ តុលា ឆ្នាំ ២00២ កថាខណ្ឌ ៦ "អង្គជំនុំជម្រះពុំជាប់កាតព្វកិច្ចក្នុងការពិនិត្យរៀងរាល់កត្តាដែលអាចមាន និងដែលខ្លួនត្រូវពិចារណានៅពេលធ្វើការសម្រេចសេចក្តី ពាក់ព័ន្ធនឹងការដែលខ្លួនរកឃើញថា ប្រសិនបើនៅពេលដោះលែងជនជាប់ចោទ តើជនជាប់ចោទនឹងចូលមកបង្ហាញខ្លួនក្នុងពេលជំនុំជម្រះក្តីដែរឬយ៉ាងណានោះទេ។ ប៉ុន្តែ អង្គជំនុំជម្រះត្រូវតែចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុ។ ប្រការតម្រូវឱ្យអង្គជំនុំជម្រះបញ្ជាក់រាល់កត្តាដែលពាក់ព័ន្ធទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងដែលប្រកបដោយវិចារណញ្ញាណមួយ ត្រូវយកមកពិចារណាមុននឹងចេញសេចក្តីសម្រេច។ ចំពោះការអនុវត្តការដោះលែងជាបណ្តោះអាសន្ននាពេលបច្ចុប្បន្ននេះវិញ គេរំពឹងទុកថា អង្គជំនុំជម្រះសាលាដំបូងដែលប្រកបដោយវិចារណញ្ញាណមួយពិតជាពិចារណាកត្តាមួយចំនួនដូចខាងក្រោម..." (អត្ថបទចុងទំព័រត្រូវបានលុបចេញ)។

[៨] មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ប្រយោគទីពីរចែងថា "ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ។ នៅ[illegible] សវនាការ ឬ នៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម"។



[illegible] SUPREME COURT CHAMBER * E.C.C.C. * CHAMBRE DE LA COUR SUPREME

១២ ចំពោះកាលៈទេសៈជាក់ស្តែងនៃករណីដែលកំពុងមាននៅក្នុងដៃ គឺជនជាប់ចោទត្រូវបានជាប់ឃុំត្រឹមត្រូវតាមច្បាប់ នៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១១។ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចឃុំខ្លួនជនជាប់ចោទ ដោយអនុលោមទៅតាមវិធាន ៨២(១) លើកលែងតែខ្លួនបានសម្រេចដោះលែងរូបគាត់ ដោយអនុលោមទៅតាមវិធាន ៨២(២)។ សំណើរបស់ជនជាប់ចោទ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដោះលែងគាត់ឱ្យនៅក្រៅឃុំនោះ គឺផ្អែកលើការលើកឡើងថា រយៈពេលកំណត់បួនខែ ដែលមានចែងក្នុងវិធាន ៦៨(២)-(៣) បានផុតរលត់នាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១១ និងថា ពុំមានមូលដ្ឋានច្បាប់ដើម្បីឃុំខ្លួនគាត់បន្ទាប់ពីថ្ងៃនោះបានទេ (មូលដ្ឋានទីមួយនៃបណ្តឹងសាទុក្ខ)។ អំណះអំណាងរបស់ជនជាប់ចោទ ដែលថាលក្ខខណ្ឌក្នុងវិធាន ៦៣(៣)(ខ) ពុំត្រូវបានបំពេញនោះ គឺធ្វើឡើងគ្រាន់តែបន្ទាប់បន្សំប៉ុណ្ណោះ បន្ថែមលើអំណះអំណាងសំខាន់របស់ខ្លួន ពាក់ព័ន្ធនឹងវិធាន ៦៨(២)-(៣)[៩]។ ក្នុងកាលៈទេសៈបែបនេះ ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសលើអង្គច្បាប់ ដោយបានចេញដីកាបង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ ដោយផ្អែកលើវិធាន ៦៣(៣)(ខ)(iii)[១០]។ អង្គជំនុំជម្រះសាលាដំបូង គួរតែស្វែងរកមូលដ្ឋានសម្រាប់ការបន្តឃុំខ្លួននេះ ពីវិធាន ៨២(១) តែប៉ុណ្ណោះ។

១៣ ទោះជាយ៉ាងនេះក្តី ក៏កំហុសឆ្គងនេះ ពុំប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដែលថា ជនជាប់ចោទត្រូវបន្តឃុំខ្លួនរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ កំហុសនេះពុំបង្កើតបានជាកំហុសផ្នែកអង្គច្បាប់ដែលនាំឱ្យបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះដែរ។ ដូច្នេះ បណ្តឹងសាទុក្ខលើមូលដ្ឋាននេះ ត្រូវបានបដិសេធ។

១៤ យោងតាមហេតុផលដូចបានរៀបរាប់ខាងលើ ខ្ញុំជំទាស់ដោយក្តីគោរព។

---

[៩] ជនជាប់ចោទពុំបានលើកឡើងអំពីវិធាន ៦៣(៣) នៅក្នុងសំណើសុំដោះលែងរបស់គាត់ នៅចំពោះមុខអង្គជំនុំជម្រះតុលាការដំបូងទេ (Doc. E18)។ នៅពេលសវនាការ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ សហមេធាវីរបស់ជនជាប់ចោទ បានធ្វើសារណាផ្ទាល់មាត់ខ្លីមួយប៉ុណ្ណោះ ពាក់ព័ន្ធនឹងវិធាន ៦៣(៣) នេះ (សូមមើល ប្រតិចារឹករបស់សវនាការ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ Doc. E1/1.1, ទំព័រទី ៣១ បន្ទាត់ទី ៥, ទំព័រទី ៣៤ បន្ទាត់ទី ១២, ទំព័រទី ៤១ បន្ទាត់ទី ៣, ទំព័រទី ៤២ បន្ទាត់ទី ២៥ និង ទំព័រទី ៧៩ បន្ទាត់ទី ២០ ទំព័រទី ៨៣ បន្ទាត់ទី ២)។

[១០] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥ "ចៅក្រម [អង្គជំនុំជម្រះសាលាដំបូង] បានអញ្ជើញគូភាគីឱ្យបញ្ជាក់អំពីជំហររបស់ខ្លួន ពាក់ព័ន្ធនឹងលក្ខខណ្ឌដែលមានចែងក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង "នៅក្នុងពេលសវនាការ" ទោះបីជា[illegible] មេធាវីការក្តី ដែលបានស្នើសុំដោះលែងនោះ ពុំឈរលើមូលដ្ឋានច្បាប់ត្រង់ចំណុចនេះក៏ដោយ"។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C 9

០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក(០៤)

ឯកសារលេខ.E50/3/1/4.1

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១

**ហត្ថលេខា**

**ចៅក្រម Motoo NOGUCH**

Original EN: 00705160-00705165